ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

លេខ..០០១......សហវ

ថ្ងៃអង្គារ ១៤រោច ខែ មាឃ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ មីនា ឆ្នាំ២០១៩

**សារាចរណែនាំ**

**ស្តីពី**

**ការតម្កល់ប្រាក់ធានាការដេញថ្លៃ និងការតម្កល់ប្រាក់ធានាការអនុវត្តកិច្ចសន្យា ក្នុងកិច្ចលទ្ធកម្មសាធារណៈ**

អនុលោមតាមប្រកាសលេខ ៩៨៦ សហវ.ប្រក ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៦ ស្តីពីប្រាក់កក់ធានាការដេញថ្លៃ និងប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមណែនាំដល់គ្រប់ស្ថាប័នអនុវត្តលទ្ធកម្មនិងអង្គភាពថវិកា អំពីនីតិវិធីនៃការកក់ប្រាក់ធានាការដេញថ្លៃ និងការកក់ប្រាក់ធានាការអនុវត្តកិច្ចសន្យា ដែលមាន២ជម្រើស ដូចខាងក្រោម÷

**ជម្រើសទី១**÷ ប្រាក់កក់ធានាការដេញថ្លៃ និងប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា អ្នកដេញថ្លៃ អ្នកផ្គត់ផ្គង់ ឬអ្នកទទួលការ អាចកក់នៅអគ្គនាយកដ្ឋានរតនាគារជាតិឬនៅរតនាគាររាជធានី ខេត្ត ដោយកក់ចូលគណនីប្រាក់កក់របស់អគ្គនាយកដ្ឋានរតនាគារជាតិ ឬរតនាគាររាជធានី ខេត្ត (ដែលមានបើកនៅ ១.ធនាគារជាតិនៃកម្ពុជា ២.ធនាគារ កាណាឌីយ៉ា ក.អ និង ៣. ធនាគារ អេស៊ីលីដា ភីអិលស៊ី) ហើយអគ្គនាយកដ្ឋានរតនាគារជាតិ ឬរតនាគាររាជធានី ខេត្ត ត្រូវចេញលិខិតធានាប្រាក់កក់ធានាការដេញថ្លៃ និងប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា ជូនស្ថាប័នអនុវត្តលទ្ធកម្ម ឬអង្គភាពថវិកាពាក់ព័ន្ធ។

**ជម្រើសទី២**÷ ប្រាក់កក់ធានាការដេញថ្លៃ និងប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា អ្នកដេញថ្លៃ អ្នកផ្គត់ផ្គង់ ឬអ្នកទទួលការ អាចកក់នៅធនាគារពាណិជ្ជជាដៃគូណាមួយ (ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ) ដែលបានចុះអនុស្សរណៈនៃការយោគយល់គ្នាជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ហើយធនាគារពាណិជ្ជដៃគូ ត្រូវចេញលិខិតធានា (Bank Guarantee) ប្រាក់កក់ធានាការដេញថ្លៃ និងប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា ជូនស្ថាប័នអនុវត្តលទ្ធកម្ម ឬអង្គភាពថវិកាពាក់ព័ន្ធ។

ចំពោះនីតិវិធីនៃការបង្វែរសងប្រាក់កក់ឬការរឹបអូសប្រាក់កក់ ត្រូវអនុលោមតាមខ្លឹមសារនៃប្រកាសលេខ៩៨៦ សហវ.ប្រក ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៦ ស្តីពីប្រាក់កក់ធានាការដេញថ្លៃ និងប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា។

គ្រប់ស្ថាប័នអនុវត្តលទ្ធកម្មនិងអង្គភាពថវិកា ត្រូវសហការអនុវត្តតាមខ្លឹមសារនៃសារាចរណែនាំនេះឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**បណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល÷**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន មន្ទីរជំនាញ
  និងអង្គភាពពាក់ព័ន្ធទាំងអស់ "ដើម្បីអនុវត្ត"
- ធនាគារពាណិជ្ជដៃគូ
  "ដើម្បីសហការអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92,Sangkat Wat Phnom , Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ: ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax: 855-23-427 798

## ឧបសម្ព័ន្ធនៃសារាចរណែនាំលេខ ០០១ សហវ ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១៩
## ស្តីពីការកក់ប្រាក់ធានាការដេញថ្លៃនិងការកក់ប្រាក់ធានាការអនុវត្តកិច្ចសន្យា
## ក្នុងកិច្ចលទ្ធកម្មសាធារណៈ

### តារាងឈ្មោះធនាគារពាណិជ្ជដៃគូ
### ដែលបានចុះអនុស្សរណៈនៃការយោគយល់គ្នាជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

| ល.រ | ឈ្មោះធនាគារ |
|---|---|
| ១ | ធនាគារ អេស៊ីលីដា ភីអិលស៊ី |
| ២ | ធនាគារ កាណាឌីយ៉ា ក.អ |
| ៣ | ធនាគារ ពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជា |
| ៤ | ធនាគារ កម្ពុជាសាធារណៈ ភីអិលស៊ី |
| ៥ | ធនាគារ វឌ្ឍនៈ |
| ៦ | ធនាគារ វឌ្ឍនៈអាស៊ី ចំកាត់ (ABA) |
| ៧ | ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី |
| ៨ | ធនាគារ មេយប៉ែង (ខេមបូឌា) ភីអិលស៊ី |
| ៩ | ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ |
| ១០ | ធនាគារ ជីប ម៉ុង ខមមើសល ប៊ែង ម.ក |
| ១១ | សាខាធនាគារ កសិកន ផាប់ប្លិក ខមភេនី លីមីធីត (ភ្នំពេញ) |
| ១២ | ធនាគារ អ៊ូរី (ខេមបូឌា) ម.ក |
| ១៣ | ធនាគារ ហុង លីអុង (ខេមបូឌា) ភីអិលស៊ី |

**កំណត់សម្គាល់:**

បច្ចុប្បន្នភាពត្រឹមថ្ងៃទី ១៧ ខែ មីនា ឆ្នាំ២០២៣

**ឧបសម្ព័ន្ធនៃសារាចរណែនាំលេខ ០០១ សហវ ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១៩**

**ស្តីពីការកក់ប្រាក់ធានាការដេញថ្លៃនិងការកក់ប្រាក់ធានាការអនុវត្តកិច្ចសន្យា**

**ក្នុងកិច្ចលទ្ធកម្មសាធារណៈ**

## តារាងឈ្មោះធនាគារពាណិជ្ជដៃគូ

## ដែលបានចុះអនុស្សរណៈនៃការយោគយល់គ្នាជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

| ល.រ | ឈ្មោះធនាគារ |
|---|---|
| ១ | ធនាគារ អេស៊ីលីដា ភីអិលស៊ី |
| ២ | ធនាគារ កាណាឌីយ៉ា ក.អ |
| ៣ | ធនាគារ ពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជា |
| ៤ | ធនាគារ កម្ពុជាសាធារណៈ ភីអិលស៊ី |
| ៥ | ធនាគារ វឌ្ឍនៈ |
| ៦ | ធនាគារ វឌ្ឍនៈអាស៊ី ចំកាត់ (ABA) |
| ៧ | ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី |
| ៨ | ធនាគារ មេយប៊ែង (ខេមបូឌា) ភីអិលស៊ី |
| ៩ | ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ |
| ១០ | ធនាគារ ជីប ម៉ុង ខមមើសល ប៊ែង ម.ក |
| ១១ | សាខាធនាគារ កសិកន ផាប់ប្លិក ខមភេនី លីមីធីត (ភ្នំពេញ) |

**កំណត់សម្គាល់:**

បច្ចុប្បន្នភាពត្រឹមថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២២

## ឧបសម្ព័ន្ធនៃសារាចរណែនាំលេខ ០០១ សហវ ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១៩
## ស្តីពីការកក់ប្រាក់ធានាការដេញថ្លៃនិងការកក់ប្រាក់ធានាការអនុវត្តកិច្ចសន្យា
## ក្នុងកិច្ចលទ្ធកម្មសាធារណៈ

### តារាងឈ្មោះធនាគារពាណិជ្ជដៃគូ
### ដែលបានចុះអនុស្សារណៈនៃការយោគយល់គ្នាជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

| ល.រ | ឈ្មោះធនាគារ |
|---|---|
| ១ | ធនាគារ អេស៊ីលីដា ភីអិលស៊ី |
| ២ | ធនាគារ កាណាឌីយ៉ា ក.អ |
| ៣ | ធនាគារ ពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជា |
| ៤ | ធនាគារ កម្ពុជាសាធារណៈ ភីអិលស៊ី |
| ៥ | ធនាគារ វឌ្ឍនៈ |
| ៦ | ធនាគារ វឌ្ឍនៈអាស៊ី ចំកាត់ (ABA) |
| ៧ | ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី |
| ៨ | ធនាគារ មេយប៊ែង (ខេមបូឌា) ភីអិលស៊ី |
| ៩ | ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ |
| ១០ | ធនាគារ ជីប ម៉ុង ខមមើសល ប៊ែង ម.ក |

**កំណត់សម្គាល់:**

បច្ចុប្បន្នភាពត្រឹមថ្ងៃទី១០ ខែមករា ឆ្នាំ២០២២

**ឧបសម្ព័ន្ធនៃសារាចរណែនាំលេខ ០០១ សហវ ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១៩**
**ស្តីពីការកក់ប្រាក់ធានាការដេញថ្លៃនិងការកក់ប្រាក់ធានាការអនុវត្តកិច្ចសន្យាក្នុង**
**កិច្ចលទ្ធកម្មសាធារណៈ**

## តារាងឈ្មោះធនាគារពាណិជ្ជដៃគូ
## ដែលបានចុះអនុស្សរណៈនៃការយោគយល់គ្នាជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

| ល.រ | ឈ្មោះធនាគារ |
|---|---|
| ១ | ធនាគារអេស៊ីលីដា ភីអិលស៊ី |
| ២ | ធនាគារកាណាឌីយ៉ា ក.អ |
| ៣ | ធនាគារពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជា |
| ៤ | ធនាគារកម្ពុជាសាធារណៈ ភីអិលស៊ី |
| ៥ | ធនាគារវឌ្ឍនៈ |
| ៦ | ធនាគារវឌ្ឍនៈអាស៊ី ចំកាត់ |
| ៧ | ធនាគារស៊ីអាយអិមប៊ី ភីអិលស៊ី |

**កំណត់សម្គាល់:**

បច្ចុប្បន្នភាពត្រឹមថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៩

**ឧបសម្ព័ន្ធនៃសារាចរណែនាំលេខ ០០១ សហវ ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១៩**
**ស្តីពីការកក់ប្រាក់ធានាការដេញថ្លៃនិងការកក់ប្រាក់ធានាការអនុវត្តកិច្ចសន្យាក្នុង**
**កិច្ចលទ្ធកម្មសាធារណៈ**

## តារាងឈ្មោះធនាគារពាណិជ្ជដៃគូ
## ដែលបានចុះអនុស្សរណៈនៃការយោគយល់គ្នាជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

| ល.រ | ឈ្មោះធនាគារ |
|---|---|
| ១ | ធនាគារអេស៊ីលីដា ភីអិលស៊ី |
| ២ | ធនាគារកាណាឌីយ៉ា ក.អ |
| ៣ | ធនាគារពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជា |
| ៤ | ធនាគារកម្ពុជាសាធារណៈ ភីអិលស៊ី |
| ៥ | ធនាគារវឌ្ឍនៈ |
| ៦ | ធនាគារវឌ្ឍនៈអាស៊ី ចំកាត់ |
| ៧ | ធនាគារស៊ីអាយអិមប៊ី ភីអិលស៊ី |
| ៨ | ធនាគារ មេយប៉ែង (ខេមបូឌា) ភីអិលស៊ី |
| ៩ | ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ |

**កំណត់សម្គាល់:**
បច្ចុប្បន្នភាពត្រឹមថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២០

ព្រះរាជាណាចក្រកម្ពុជា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ